# ពិធីសម្ពោធជាផ្លូវការក្រុមហ៊ុនអាយប៊ីសរ៉ាយស៍ ខន់សើវេសិន

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០២០ អង្គការ WCS ក្រុមហ៊ុនអាយប៊ីសរ៉ាយស៍ ខន់សេវេសិន និងអង្គការសន្សំម្លប់ព្រៃ (SMP) មានកិត្តិយសដោយបានឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង**លោកជំទាវ** ព្រមទាំងប្រតិភូ អញ្ជើញចូលរួមអធិបតីសម្ពោធជាផ្លូវការក្រុមអាយប៊ីសរ៉ាយស៍ ខន់សេវេសិន ស្ថិតនៅសង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ និងពិនិត្យមើលខ្សែសង្វាក់វេចខ្ចប់អង្គការមិត្តភាពសង្គ្រោះសត្វព្រៃរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនអាយប៊ីសរ៉ាយស៍ ត្រូវបានបង្កើតឡើងដោយអង្គការសមាគមន៍អភិរក្សសត្វព្រៃ )WCS( និងបានដាក់ឈ្មោះ តាមសត្វត្រយងយក្ស ចាយអឺន អាយប៊ីស)- Giant Ibis( ដែលជាបក្សីជាតិតំណាងឱ្យប្រទេសកម្ពុជា។ សត្វត្រយងយក្ស គឺប្រភេទបក្សីដែលមានមាឌធំជាងគេបំផុតនៅលើពិភពលោក ហើយដោយសារតែសត្វនេះជាប្រភេទបក្សីកម្រ បានធ្វើឱ្យអ្នកចូលចិត្តទស្សនាសត្វស្លាប និងក្រុមអ្នកអភិរក្សគិតថាប្រភេទនេះស្ទើរតែលែងមានវត្តមាននៅលើពិភពលោកនេះទៅហើយ។ ត្រយងយក្ស ត្រូវបានចាត់ចំណាត់ថ្នាក់ជាប្រភេទជិតផុតពូជបំផុត ជាពិសេសដោយសារឥទ្ធិពល នៃការរំខានរបស់មនុស្សនិងការបរបាញ់។ សត្វត្រយងយក្សដែលនៅសេសសល់បានប្រមូលផ្តុំគ្នាទៅរស់នៅក្នុងតំបន់ ភាគខាងជើងនៃប្រទេសកម្ពុជា។ ក្នុងឆ្នាំ ២០០៩ អង្គការ WCS ក្រោមការគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគម្រោងស្រូវអាប៊ីស ដែលជាវិធីសាស្ត្រមួយជួយគាំទ្រដល់ការអភិរក្សប្រភេទនេះ។ គម្រោងនេះមានគោលបំណងលើកទឹកចិត្តដល់សហគមន៍មូលដ្ឋានឱ្យចូលរួមអភិរក្ស តាមរយៈការទិញស្រូវសរីរាង្គពូជផ្ការំដួលក្នុងតម្លៃមួយខ្ពស់បំផុតពីក្រុមកសិករផលិតដែលបានប្តេជ្ញាចិត្តចូលរួមការពារព្រៃឈើនិងឈប់បរបាញ់សត្វព្រៃ។ គម្រោងនេះបានរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ក្រុមកសិករគោលដៅ ស្របពេលជាមួយគ្នាដែរគឺដោះស្រាយកត្តាគំរាមកំហែងចំបងៗចំពោះប្រភេទជិតផុតពូជបំផុត រួមទាំងសត្វត្រយងយក្ស និងការគំរាមកំហែងដល់ទីជម្រករបស់វាតាមរយៈការកាប់រានដីព្រៃនិងតំបន់ដីសើមយកធ្វើជាស្រែសម្រាប់ដាំស្រូវ។

ក្រុមហ៊ុន អាយប៊ីសរ៉ាយស៍ ត្រូវបានបង្កើតឡើងដោយអង្គការសមាគមន៍អភិរក្សសត្វព្រៃក្នុងឆ្នាំ ២០១៧ ដើម្បីបំពេញសក្តានុពលនៃផលិតផលនេះនិងបង្កើនការផលិត។ បច្ចុប្បន្ន ក្រុមហ៊ុន អាយប៊ីសរ៉ាយស៍ ធ្វើការជាមួយកសិករសង្គ្រោះសត្វព្រៃចំនួន ១៥០ភាគរយខ្ពស់ជាងតម្លៃទីផ្សារសម្រាប់ស្រូវសរីរាង្គមិត្ត ៥០០គ្រួសារ ដោយផ្តល់នូវតម្លៃលក់ចេញ. ភាពសង្គ្រោះសត្វព្រៃពូជផ្ការំដួល។ កសិករបានប្តេជ្ញាមិនកាប់ឈើ មិនបរបាញ់សត្វព្រៃ ឬប្រើប្រាស់សារធាតុគីមីពុលដើម្បីចូលរួមការពារតំបន់ការពារនិងប្រភេទកម្រនៅក្នុងតំបន់នេះ។ អង្ករនេះត្រូវបានទទួលស្គាល់ថាជាប្រភេទអង្ករសរីរាង្គនិងរួមចំណែកក្នុងការសង្គ្រោះសត្វព្រៃតាមស្តង់ដាទីផ្សារសហភាពអឺរ៉ុបនិងក្រសួងកសិកម្មអាមេរិក។ បច្ចុប្បន្ន អង្ករនេះមានលក់នៅលើទីផ្សារពិភពលោកក្នុងតម្លៃខ្ពស់ រួមទាំងទីផ្សារនៅអឺរ៉ុបនិងប្រទេសកាណាដាផងដែរ។ គម្រោងនេះបានចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់កសិករគោលដៅ ព្រមទាំងបានជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើបាន ៧៥ភាគរយនៅក្នុងតំបន់នានាដែលកសិកររស់នៅនិងដាំដុះដំណាំ។ គុណភាពអង្ករផ្ការំដួល និងដំណើររឿងដែលកើតឡើងព្រមគ្នា មានន័យថា បរិមាណតម្រូវការអង្ករអាប៊ីសនៅលើទីផ្សារអន្តរជាតិលើសបរិមាណផ្គត់ផ្គង់។ ដោយសារក្រុមហ៊ុន អាយប៊ីស ជ្រើសរើសនិងបណ្តុះបណ្តាលកសិករបន្ថែមទៀត ដូច្នេះក្រុមហ៊ុនត្រូវការទុនបង្វិលបន្ថែមទៀតដើម្បីបង្កើនបរិមាណនៃការទិញស្រូវឱ្យបានច្រើនជាងនេះទៀត។

ឯកឧត្តម **សាយ សំអាល់** បានមានប្រសាសន៍ថា «ផលិតផលដែលផលិតឡើងដោយគិតគូរដល់ការអភិរក្សសត្វព្រៃផងនិងផ្អែកលើគោលការណ៍សរីរាង្គផង គឺជាវិធីសាស្ត្រដ៏ល្អមួយក្នុងការទទួលបាននូវតម្លៃទីផ្សារខ្ពស់ ហើយយើងគួរតែ

ទិញផលិតផលទាំងនេះពីកសិករដែលបានអនុវត្តគម្រោងនេះក្នុងតម្លៃខ្ពស់។ យើងមានផែនការគាំទ្រឱ្យគម្រោងនេះឱ្យដំណើរការទៅមុខបានល្អ។»

ឯកឧត្តមរដ្ឋមន្ត្រីបានមានប្រសាសន៍បន្ថែមថា ក្រសួងបរិស្ថានសូមលើកទឹកចិត្តដល់កសិករនៅក្នុងតំបន់ការពារធម្មជាតិឱ្យចូលរួមអនុវត្តគម្រោងនេះឱ្យបានកាន់តែសកម្មថែមទៀត។ ឯកឧត្តម ក៏បានស្នើផងដែរឱ្យអង្គការ WCS និងអង្គការ SMP ពង្រីកគម្រោងនេះទៅកាន់តំបន់ផ្សេងៗទៀត និងសំណូមពរឱ្យអតិថិជននិងប្រជាពលរដ្ឋកម្ពុជានៅក្នុងប្រទេសជួយគាំទ្រដល់អង្ករមិត្តភាពសង្គ្រោះសត្វព្រៃនេះ។

ក្រោយពិធីសម្ពោធនិងទស្សនាខ្សែសង្វាក់វេចខ្ចប់ ប្រតិភូបានទស្សនាវីដេអូនិងស្តាប់បទបង្ហាញស្តីពីវដ្តនៃការផលិតស្រូវមិត្តភាពសង្គ្រោះសត្វព្រៃ សមិទ្ធិផល និងបញ្ហាប្រឈមរបស់ក្រុមហ៊ុនក្នុងរយៈពេលកន្លងមក ព្រមទាំងបានពិភាក្សារកវិធីសាស្រ្តថាតើអង្គការ WCS អង្គការ SMP និងក្រុមហ៊ុនអាយប៊ីសរ៉ាយស៍ ត្រូវសហការគ្នាយ៉ាងដូចម្តេចដើម្បីពង្រីកគម្រោងជោគជ័យនេះបន្ថែម ហើយត្រូវរួមគ្នាដោះស្រាយបញ្ហាប្រឈមដោយវិធីណា។ លោក នីក ស្ពេនស៊័រ (Nick Spencer) នាយកក្រុមហ៊ុនអាយប៊ីសរ៉ាយស៍ បានមានប្រសាសន៍ថា «អតិថិជនគាំទ្រនិងឱ្យតម្លៃលើផលិតផលនិងគុណភាពអង្ករមិត្តភាពសង្គ្រោះសត្វព្រៃរបស់យើងដោយសារអង្ករនេះផលិតតាមគោលការណ៍សរីរាង្គ។ ក៏ប៉ុន្តែ មូលហេតុចម្បងដែលនាំឱ្យអតិថិជនទិញអង្កររបស់យើងគឺដោយសារអង្ករនេះបានផ្សារភ្ជាប់ទៅនឹងការអភិរក្សនិងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាកសិករ។ ការផ្គត់ផ្គង់នូវផលិតផលមួយជូនអតិថិជនដែលគេអាចជឿទុកចិត្តបាន យើងមានគោលការណ៍អនុវត្តតឹងរឹងដែលក្រុមកសិករគោលដៅត្រូវតែគោរពនិងអនុវត្តតាម ហើយជាលទ្ធផលធុរកិច្ចរបស់យើងអាចផ្តល់តម្លៃនោះត្រឡប់ទៅកសិករវិញបាន។ ក៏ប៉ុន្តែ មានសម្ពាធនិងហានិភ័យជាច្រើនកើតមានចំពោះការធ្វើកសិកម្មតាមវិធីនេះនៅពេលដែលដីព្រៃត្រូវបានគេកាប់រាន និងថ្នាំគីមីពុលត្រូវបានមនុស្សចំណូលថ្មីនៅក្នុងសហគមន៍ប្រើប្រាស់។ យើងខ្ញុំសង្ឃឹមថានឹងបានធ្វើការកាន់តែជិតស្និទ្ធជាងនេះទៀតជាមួយក្រសួងបរិស្ថាន និងអាជ្ញាធរមូលដ្ឋានដើម្បីការពារនិងពង្រីកនូវកាលនុវត្តភាពដែលមានសក្តានុពលពិតប្រាកដ។»

លោក កែន សេរីរដ្ឋា នាយកអង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា បានមានប្រសាសន៍ថា «ការសម្រេចបានលើការងារអភិរក្សតម្រូវឱ្យយើងត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍នៅក្នុងដែនជម្រកសត្វព្រៃ ដើម្បីធានាថា គោលបំណងរបស់ពួកគាត់ត្រូវបានឆ្លើយតប ស្របពេលដែលទីជម្រកសត្វព្រៃនៅជុំវិញតំបន់ដែលប្រជាសហគមន៍រស់នៅត្រូវបានការពារផងដែរ។ គម្រោងស្រូវមិត្តភាពសង្គ្រោះសត្វព្រៃអាចជាឧត្តមានុវត្តមួយដែលមានការទទួលស្គាល់ជាសកល។»

********* * *********

*សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖*

*ឯកឧត្តម នេត្រ ភក្ត្រា*
*រដ្ឋលេខាធិការក្រសួងបរិស្ថាន*

*លោក កែវ សុជាតិ*
*នាយកប្រតិបត្តិ អង្គការសន្សំម្លប់ព្រៃ*
*ទូរស័ព្ទ៖ ០៨៦ ៥៥ ០០ ២៧*

*លោក លាក់ រតនា*
*ប្រធានកិច្ចការទំនាក់ទំនង*
*អង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា*
*ទូរស័ព្ទ៖ ០១២ ៨១៩១២១*